

## តើខ្ញុំអាចទទួលបានអាហារអ្វីខ្លះពី WIC?

WIC ធ្វើអោយអ្នកកាន់តែងាយស្រួលក្នុងការផ្តល់នូវអាហារសុខភាពមានឱជារសដែលអ្នកមានអារម្មណ៍ល្អអំពីការផ្តល់ទៅដល់គ្រួសាររបស់អ្នក ។ WIC ផ្តល់នូវអាហារសុខភាពឥតគិតថ្លៃ ដែលរួមមាន៖

- ម្ហូបកូនង៉ែត
- អង្ករសំរូប
- ត្រីខកំប៉ុង
- អាហារគ្រៀមៗ
- ឈីស្ស
- សណ្តែកគ្រៀម ឬកំប៉ុង/សណ្តែកបារាំង
- ពងមាន
- ទឹកផ្លែឈើ
- ផ្លែឈើ និងបន្លែ
- ទឹកដោះគោកូនង៉ែត
- ទឹកដោះគោ
- ប៊ឺរសណ្តែកដី
- នំគ្រៀបធ្វើពីម្សៅពោត
- នំប៉័ងធ្វើពីធញ្ញជាតិសុទ
- តៅហ៊ូ

WIC follow the sun to GOOD FOOD

ឥឡូវនេះ WIC បើកឲ្យប្រើប័ណ្ណអត្ថប្រយោជន៍អេឡិចត្រូនិក ហើយកម្មវិធី ‘WIC Shopper’ គឺជាអ្វីសម្រាប់ជួយអ្នកក្នុងការទិញអីវ៉ាន់បានកាន់តែងាយស្រួលជាងមុន និងលឿនជាងពេលណាៗទាំងអស់!

ដើម្បីឲ្យបានដឹងអំពីកម្មវិធ WIC សូមទូរស័ព្ទទៅលេខ 1-800-942-1007 ឬកម្មវិធីមួយដែលស្ថិតនៅជិតអ្នក ។

### តំបន់ បុស្តុន

| | |
|---|---|
| Cambridge/Somerville | (617) 575-5330 |
| Chelsea/Revere | (617) 887-4340 |
| Dorchester North/Mattapan | (617) 825-8994 |
| Dorchester South/South Boston | (617) 825-0805 |
| East Boston | (617) 568-6440 |
| Jamaica Plain/Brighton | (617) 983-6086 |
| Roxbury/South End | (617) 989-3055 |
| South Cove | (617) 521-6777 |

### តំបន់ កាព

| | |
|---|---|
| Cape Cod | (508) 771-7896 |
| Outer Cape | (508) 240-0853 |

### ប៉ែក កណ្តាល

| | |
|---|---|
| Framingham/Waltham | (508) 620-1445 |
| North Central | (978) 345-6272 |
| South Central | (508) 765-0139 |
| Worcester | (508) 796-7000 |

### ប៉ែក ឦសាន

| | |
|---|---|
| Lawrence | (978) 681-4960 |
| Lowell | (978) 454-6397 |
| North Shore | (781) 599-7290 |
| North Suburban | (781) 338-7578 |
| Northern Essex | (978) 374-2191 |

### ប៉ែក អាគ្នេយ

| | |
|---|---|
| Brockton | (508) 588-8241 |
| Fall River | (508) 679-9349 |
| New Bedford | (508) 997-1500 |
| Plymouth | (508) 747-4933 |
| Quincy | (617) 376-8701 |
| Taunton/Attleboro | (508) 823-6346 |

### ប៉ែក ខាងលិច

| | |
|---|---|
| Berkshire North | (413) 447-3495 |
| Berkshire South | (413) 528-0457 |
| Franklin/Hampshire/No. Quabbin | (413) 376-1160 |
| Holyoke/Chicopee | (413) 534-2460 |
| Springfield North | (413) 737-8868 |
| Springfield South | (413) 693-1029 |

**www.mass.gov/wic**

ស្ថាប័ននេះគឺជាអ្នកផ្តល់ឱកាសស្មើភាពគ្នា។

Form #147

# WIC

## ការផ្តល់ជូនគ្រួសារ នូវអាហារដ៏ល្អៗ និងច្រើនសន្ធឹកថែមទៀត









**1-800-942-1007**

@MassWIC

2020



# តើកម្មវិធី WIC ជាអ្វី?

WIC គឺជាកម្មវិធីអាហារមានជីវជាតិ ដែលផ្តល់អាហារមានជីវជាតិ និងផ្តល់ការអប់រំ សុខភាព ផ្តល់អាហារមានសុខភាពល្អ និងការបំរើផ្សេងៗទៀត ដោយឥតគិតថ្លៃសោះ សំរាប់គ្រួសារនៅរដ្ឋម៉ាស្សាជូសេត្ត ដែលមានសិទ្ធិទទួល ។ WIC ជាតំណាងឲ្យពាក្យ ស្ត្រី ទារក និងកុមារ (Women, Infants and Children) ។

## តើកម្មវិធី WIC ផ្តល់ជូនអ្វីខ្លះ?

គោលដៅរបស់កម្មវិធី WIC គឺដើម្បីជួយរក្សាស្ត្រីមានផ្ទៃពោះ និងស្ត្រីបំបៅដោះកូន ព្រមទាំងក្មេងៗក្រោមអាយុ 5 ឆ្នាំ ឲ្យមានសុខភាពល្អ ។ ដើម្បីធ្វើការនេះ កម្មវិធី WIC ផ្តល់ :

- ការប្រឹក្សាអំពីអាហារមានជីវជាតិ ដោយផ្ទាល់ខ្លួន
- អាហារសុខភាពឥតគិតថ្លៃ
- ឱវាទសំរាប់ការបរិភោគល្អ ដើម្បីធ្វើឲ្យសុខភាពល្អប្រពៃឡើង
- ការបញ្ជូនទៅថែទាំរោគា និងការថែទាំធ្មេញ ការធានារ៉ាប់រងសុខភាព ការមើលថែក្មេង ទីលំនៅ និងជំនួយប្រេងឥន្ធនៈ ព្រមទាំងការបំរើផ្សេងៗទៀត ដែលអាចផ្តល់ផលប្រយោជន៍សំរាប់គ្រួសារទាំងមូល

ប៉ុន្តែមិនទាន់អស់នៅឡើយទេ!!!  កម្មវិធី WIC ក៏ផ្តល់ថ្នាក់រៀនបំបៅដោះកូន ការគាំទ្រ មួយ-ទល់-មួយ អំពីការបំបៅដោះកូន ព្រមទាំងការត្រួតពិនិត្យចាក់ថ្នាំការពាររោគ និងការបញ្ជូនដែរ ។ កម្មវិធី WIC ក៏ផ្តល់ឱកាសឲ្យមាតាបិតា ដើម្បីនិយាយទៅកានមាតាបិតាដទៃទៀត អំពីអាហារមានជីវជាតិ និងប្រធានបទខាងសុខភាពផ្សេងៗទៀត ដែលជាសារៈសំខាន់ សំរាប់គ្រួសាររបស់គេ ផងដែរ ។



## តើកម្មវិធី WIC សំរាប់អ្នកណា?

កម្មវិធី WIC គឺសំរាប់ក្មេងៗនៃគ្រួសារ : ដែលរស់នៅជុំគ្នា និងមាតាបិតាម្នាក់ឯង, ធ្វើការ ឬមិនធ្វើការក្តី ។ បើសិនអ្នកជាឪពុក, ម្តាយ, ជីដូនជីតា, មាតាបិតាចិញ្ចឹម ឬអ្នកអាណាព្យាបាលពេញច្បាបផ្សេងទៀត នៃក្មេងក្រោមអាយុ 5 ឆ្នា អ្នកអាចដាក់ពាក្យសុំកម្មវិធី WIC សំរាប់កូនរបស់អ្នកបាន ។



អ្នកអាចចូលរួមក្នុងកម្មវិធី WIC បានបើសិនជាអ្នក :

- រស់នៅក្នុងរដ្ឋម៉ាស្សាជូសេត្ត
- ត្រូវការនូវអាហារមានជីវជាតិ (បុគ្គលិកកម្មវិធី WIC អាចជួយអ្នកសំរេចអំពីការនេះ)
- ជាក្មេងក្រោមអាយុ 5 ឆ្នាំ ឬជាស្ត្រីមានផ្ទៃពោះ ឬជាស្ត្រីបំបៅដោះកូន និង
- គ្រួសារមានប្រាក់ចំណូលតិចជាងកំរិតរបស់ WIC

កំរិតប្រាក់ចំណូលរបស់អ្នក មានសិទ្ធិទទួលកម្មវិធី WIC ជាស្វ័យប្រវត្តិ បើសិនជានៅពេលបច្ចុប្បន្ននេះ អ្នកកំពុងតែទទួល TAFDC,

| ទំហំគ្រួសារ | ប្រចាំឆ្នាំ | ប្រចាំខែ | ប្រចាំអាទិត្យ |
|---|---|---|---|
| 1 | $23,606 | $1,968 | $454 |
| 2 | 31,894 | 2,658 | 614 |
| 3 | 40,182 | 3,349 | 773 |
| 4 | 48,470 | 4,040 | 933 |
| 5 | 56,758 | 4,730 | 1,092 |
| 6 | 65,046 | 5,421 | 1,251 |
| 7 | 73,334 | 6,112 | 1,411 |
| 8 | 81,622 | 6,802 | 1,570 |

ហ្វ៊ូតស្តែម ឬ Masshealth ។ (ចំពោះសមាជិក Masshealth ដលមានគ្រួសារទទួលជំនួយ ឬការរ៉ាប់រង កំរិតប្រាក់ចំណូលពុំអាចទទួលជាស្វ័យប្រវត្តិបានឡើយ) ។ ក្មេងៗជាកូនចិញ្ចឹមក្រោមអាយុ 5 ឆ្នាំ ក៏មានសិទ្ធិទទួល កម្មវិធី WIC ជាស្វ័យប្រវត្តិដែរ ។

## តើបុរសអាចចូលរួមក្នុងកម្មវិធី WIC បានឬទេ?

កម្មវិធី WIC សូមស្វាគមន៍បុរស! កម្មវិធី WIC ទទួលស្គាល់តួនាទីដ៏សំខាន់ ដែលឪពុក ជីដូនជីតា មាតាបិតាចុង និងអ្នកអាណាព្យាបាលផ្សេងៗទៀត ក្នុងការថែរក្សាក្មេងៗ ។ យើង សូម-ជំរុញទឹកចិត្ត ឪពុក និងអ្នកមើលថែទាំងទៀតៗ នៃក្មេងៗក្រោមអាយុ 5 ឆ្នាំ ឲ្យចុះឈ្មោះ និងនាំក្មេងៗមកតាមការណាត់ជួប មកចូលរួមក្នុងការបង្វឹកបង្វឹន ខាងអាហារមានជីវជាតិល្អ និងខាងសុខភាព ព្រមទាំងប្រើសែក WIC នៅតាមហាងលក់គ្រឿងឧបភោគ ។

## របៀបដាក់ពាក្យសុំ **WIC?**

គឺអាចធ្វើបានក្នុងការចាប់ផ្តើមដាក់ពាក្យសុំ WIC តាមអនឡាញ ដោយគ្រាន់តែចូលមកកាន់ www.mass.gov/WIC ឬចូលមកកាន់ទំព័រ Mass WIC Facebook តាម @MassWIC ។ ចំពោះគ្រួសារដែលចាប់អារម្មណ៍ចង់ដាក់ពាក្យសុំ សូមចុចលើពាក្យ 'Apply for WIC' រួចផ្តល់ព័ត៌មានជាមូលដ្ឋានមួយចំនួន ដើម្បីជាការចាប់ផ្តើមដាក់ពាក្យសុំរបស់ខ្លួន ។ បើមិនដូច្នោះទេ សូមទាក់ទងជាមួយនឹងកម្មវិធី **WIC** ប្រចាំសហគមន៍របស់អ្នក ដើម្បីរៀបចំការណាត់ជួប ឬក៏ហៅទូរស័ព្ទមកកាន់លេខ 1-800-942-1007 ។ ការិយាល័យ **WIC** មួយចំនួនធំ បើកទ្វារធ្វើការនៅពេលល្ងាច និងនៅថ្ងៃសៅរ៍ ដើម្បីកុំឲ្យអ្នកត្រូវខករៀន ឬខកការងារ ។ យើងខ្ញុំស្វាគមន៍ជានិច្ចបើអ្នកចង់មកជួបយើងខ្ញុំនៅការិយាល័យផ្ទាល់!